Declassified to Public
12 April 2013

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 19 / 03 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

លេខ/No: D345/4

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Royaume du Cambodge
Nation Religion Roi

Kingdom of Cambodia
Nation Religion King

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

លេខសំណុំរឿង: ០០២/១៩-០៩-២០០៧/អ.វ.ត.ក.--ក.ស.ច.ស.

ការិយាល័យសហចៅក្រមស៊ើបអង្កេត
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 19 / 03 / 2010
ម៉ោង (Time/Heure): 15:07
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

ចំពោះមុខ ៖ ចៅក្រម យូ ប៊ុនឡេង
ចៅក្រម Marcel LEMONDE (ម៉ាសែល ឡឺម៉ុង)

កាលបរិច្ឆេទ៖ ថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០១០

ភាសា៖ ខ្មែរ/ បារាំង

ចំណាត់ថ្នាក់ឯកសារ៖ សម្ងាត់

# ដីកាសម្រេចលើសំណើលោក អៀង សារី ប្រឆាំងនឹង ការអនុវត្តទ្រឹស្តីនៃការទទួលខុសត្រូវរបស់មេកើយ នៅ អ.វ.ត.ក.

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង
លោក Andrew CAYLEY

**ជនត្រូវចោទ**

នួន ជា
ខៀវ សំផន
អៀង សារី
កាំង ហ្គេកអ៊ាវ ហៅ ឌុច
អៀង ធីរិទ្ធ

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

នី ច័ន្ទឌី
ឡោ ជុនធី
គង់ ពិសី
ហុង គឹមសួន
យុង ផានិត
គីម ម៉េងឃី
ម៉ុច សុវណ្ណារី
ស៊ីន សុវន
ជេត វណ្ណលី
ពេជ អង្គ

Silke STUDZINSKY
Françoise GAUTRY
Isabelle DURAND

Phillipe CANONNE
Elizabeth Rabesandratana
Mahdev MOHAN
Olivier BAHOUGNE
David BLACKMAN
Martine JACQUIN
Annie DELAHAIE
Fabienne TRUSSES-NAPROUS
Patrick BAUDOIN
Lyma Thuy Nguyen
Marie Guiraud
Laure DESFORGES
Christine MARTINEAU

**មេធាវីការពារក្តី**

សុន អរុណ Michiel PESTMAN
Victor KOPPE
អាង ឧត្តម Michael G.KARNAVAS
ផាត់ ពៅសៀង Diana ELLIS
សា សុវាន Jacques VERGÈS
ការ សាវុត François ROUX
Marie-Paule CANIZARÈS

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

00487595



យើង **យូ ប៊ុនឡេង** និង Marcel LEMONDE (ម៉ាសែល ឡឺម៉ុង) សហចៅក្រមស៊ើបអង្កេត **នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា** ("អ.វ.ត.ក.")

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ ("ច្បាប់ស្តីពី អ.វ.ត.ក")

បានឃើញការស៊ើបសួរលើឈ្មោះ **អៀង សារី និងជនត្រូវចោទផ្សេងទៀត** ដែលត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យចំពោះ **បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ បទប្រល័យពូជសាសន៍ ការធ្វើមនុស្សឃាត ការធ្វើទារុណកម្ម និងការវាយប្រហារលើសាសនា** បទល្មើសដែលមានចែង និងផ្តន្ទាទោស តាមមាត្រា ៣, ៤, ៥, ៦, ២៩(ថ្មី) និង៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងមាត្រា២០៩, ២១០, ៥០០, ៥០១, ៥០៣ ដល់ ៥០៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦

បានឃើញវិធាន៣៨, ៣៩(៦), ៥៥(៥), ៥៥(១០) និង៦៧(២) នៃវិធានផ្ទៃក្នុង អ.វ.ត.ក ("វិធានផ្ទៃក្នុង")

បានឃើញមាត្រា៥.១ និង៥.៤ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក (សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ)

បានឃើញសំណើរបស់មេធាវីការពារក្តី អៀង សារី សុំបន្ថែមចំនួនទំព័រដែលបានកំណត់ ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១០ (D345)

បានឃើញដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចលើសំណើសុំបន្ថែមចំនួនទំព័រដែលបានកំណត់ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១០ (D345/1)

បានឃើញសំណើរបស់មេធាវីការពារក្តី អៀង សារី ប្រឆាំងនឹងការអនុវត្តទ្រឹស្តីនៃការទទួលខុសត្រូវរបស់មេកើយនៅ អ.វ.ត.ក ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០១០ (D345/2 - សំណើលើកទី១)

បានឃើញសំណើជម្រើសរបស់មេធាវីការពារក្តី អៀង សារី ប្រឆាំងនឹងការអនុវត្តទ្រឹស្តីនៃការទទួលខុសត្រូវរបស់មេកើយ នៅ អ.វ.ត.ក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១០ (D345/3 - សំណើជម្រើស)

## ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១០ ក្រុមមេធាវីការពារក្តី អៀង សារី បានដាក់សំណើបន្ថែមចំនួនទំព័រដែលបានកំណត់ ដើម្បីនឹងដាក់សេចក្តីសន្និដ្ឋានទាក់ទងនឹងការអនុវត្តទ្រឹស្តីនៃការទទួលខុសត្រូវ

របស់មេកើយ នៅ អ.វ.ត.ក[១]។ ក្រុមមេធាវីបានអះអាងថា វាមានស្ថានភាពពិសេសក្នុងករណីនេះ ព្រោះថា សំណើនេះមានការពាក់ព័ន្ធនឹងទម្រង់នៃការទទួលខុសត្រូវ ដែលមិនអាចយកមកអនុវត្តបាននៅ អ.វ.ត.ក។

២. តាមរយៈដីកាចុះថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេត (ស.ច.ស) បានបដិសេធសំណើបន្ថែមចំនួនទំព័រដែលបានកំណត់នេះ[២]។ សហចៅក្រមស៊ើបអង្កេតបានបង្គាប់ឱ្យសហមេធាវី *"ដាក់អំណះអំណាងទាំងអស់របស់ខ្លួន នៅក្នុងពាក្យសុំតែមួយដែលស្ថិតក្នុងចំនួនទំព័រដែលបានកំណត់"* និងបានដាស់តឿនថា "រាល់ការដាក់ពាក្យសុំបន្ថែមទៀតដែលមិនគោរពតាមបទប្បញ្ញត្តិនៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ នឹងត្រូវបានចាត់ទុកថាជាការរំលោភនីតិវិធី"[៣]។

៣. នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១០ សហមេធាវីការពារក្តី អៀង សារី បានដាក់សំណើលើកទីមួយរបស់ខ្លួន ដោយស្នើឱ្យសហចៅក្រមស៊ើបអង្កេតបដិសេធការអនុវត្តការទទួលខុសត្រូវរបស់មេកើយ នៅ អ.វ.ត.ក។ សំណើទីមួយនេះបានលើកឡើងថា ការទទួលខុសត្រូវរបស់មេកើយមិនត្រូវបានទទួលស្គាល់នៅក្នុងច្បាប់កម្ពុជា ឬច្បាប់ទំនៀមទំលាប់អន្តរជាតិឡើយ។

៤. នៅថ្ងៃដដែលនោះ សហមេធាវីការពារក្តី អៀង សារី បានដាក់សំណើជម្រើសទីពីររបស់ខ្លួនស្តីពីប្រធានបទដដែលនេះ។ សំណើជម្រើសនេះបានលើកឡើងថា ក្នុងករណីមានការពិចារណាបញ្ចូលការទទួលខុសត្រូវរបស់មេកើយទៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក សហចៅក្រមស៊ើបអង្កេតគួរយល់ថា មានបញ្ហាផ្នែកអង្គហេតុ និងអង្គច្បាប់ជាច្រើននៅក្នុងការអនុវត្តទ្រឹស្តីនេះនៅ អ.វ.ត.ក។

## សំអាងហេតុនៃសេចក្តីសម្រេច

៥. សំណើផ្សេងៗដែលកំពុងត្រូវបានពិចារណា នៅក្នុងដីកានេះរួមមានបញ្ហាពីរគឺ៖ ទីមួយ ការមិនគោរពតាមការណែនាំ និងការដាស់តឿននៅក្នុងដីកា ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១០ របស់សហចៅក្រមស៊ើបអង្កេត និងទីពីរ សំណើបកស្រាយច្បាប់។

---

[១] D345

[២] D345/1

[៣] D345/1 កថាខណ្ឌ៧

00487597



***ការមិនគោរពតាមការណែនាំ និងការដាស់តឿនរបស់សហចៅក្រមស៊ើបអង្កេត***

៦. តាមរយៈដីកាចុះថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេតបានបង្គាប់ឱ្យសហមេធាវីការពារក្តី អៀង សារី ដាក់សំណើទាំងអស់ទាក់ទងនឹងការអនុវត្តការទទួលខុសត្រូវរបស់មេកើយ នៅក្នុងពាក្យសុំតែមួយដែលស្ថិតក្នុងចំនួនទំព័រដែលបានកំណត់[៤]។ សហចៅក្រមស៊ើបអង្កេតបានដាស់តឿនសហមេធាវី យោងតាមវិធាន៣៨ នៃវិធានផ្ទៃក្នុង ថា សហចៅក្រមស៊ើបអង្កេតចាត់ទុកការដាក់សំណើដដែលៗលើបញ្ហាដូចគ្នា ឬការចង់ចៀសវាងមិនគោរពការកំណត់ចំនួនទំព័រដែលបានចែងយ៉ាងច្បាស់នៅក្នុងមាត្រា៥.១ និង៥.៤ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ ថាជាការរំលោភនីតិវិធី"[៥]។

៧. សហមេធាវីការពារក្តី អៀង សារី មិនបានគោរពសេចក្តីបង្គាប់ និងការដាស់តឿននេះទាល់តែសោះ។ សហមេធាវីការពារក្តីបានដាក់សំណើពីរផ្សេងគ្នា ស្តីពីប្រធានបទតែមួយ នៅពេលដំណាលគ្នា ដែលនៅពេលបញ្ចូលគ្នាមានចំនួនទំព័រលើសពីចំនួនទំព័រដែលបានកំណត់។ សហចៅក្រមស៊ើបអង្កេតយល់ឃើញថា សហមេធាវីចង់ចៀសវាងមិនគោរពការកំណត់ចំនួនទំព័រ ដែលមានចែងយ៉ាងច្បាស់នៅក្នុងសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ តាមរយៈការដាក់សំណើជម្រើសមួយទៀត។ ទង្វើបែបនេះគឺជាការរំលោភនីតិវិធី និងជាការរំលោភលើដីការបស់សហចៅក្រមស៊ើបអង្កេត។

៨. សហចៅក្រមស៊ើបអង្កេតសូមបញ្ជាក់ឡើងវិញថា ការដាក់សំណើដដែលៗលើបញ្ហាដូចគ្នា គឺជាការចំដែល និងការខ្ជះខ្ជាយធនធានរបស់តុលាការ។ សហចៅក្រមស៊ើបអង្កេតបានចេញការដាស់តឿនមួយចំនួន ចំពោះភាគីទៅតាមវិធាន៣៨ នៃវិធានផ្ទៃក្នុងទាក់ទងនឹងការដាក់សំណើចំដែលៗ[៦] និងបានដាស់តឿនភាគីទាំងអស់ថា ការស្នើដដែលៗនឹងត្រូវទទួលការបដិសេធភ្លាមៗ[៧]។

៩. ដោយផ្អែកលើហេតុផលខាងលើ សហចៅក្រមស៊ើបអង្កេតនឹងមិនពិចារណាទៅលើសំណើជម្រើសដែលសហមេធាវីការពារក្តី អៀង សារី បានដាក់កាលពីថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ២០១០ ទេ។

---

[៤] D345/1 កថាខណ្ឌ៧

[៥] D345/1 កថាខណ្ឌ៧

[៦] សូមមើលឧទាហរណ៍នៅ D345/1 កថាខណ្ឌ ៦, D240/3 កថាខណ្ឌ ៦, D261/2 កថាខណ្ឌ១៣-១៤, D367 កថាខណ្ឌ១០-១៥

[៧] D367 កថាខណ្ឌ១៥

00487598



***សំណើបកស្រាយច្បាប់***

១០. សំណើទីមួយរបស់សហមេធាវីការពារក្ដី អៀង សារី បានស្នើឱ្យសហចៅក្រមស៊ើបអង្កេតបដិសេធការអនុវត្តការទទួលខុសត្រូវរបស់មេកើយនៅ អ.វ.ត.ក[៨]។ បើទោះជាសហមេធាវីអះអាងផ្ទុយពីនេះក្ដី[៩] លក្ខណៈនៃសំណើនេះគឺពិតជាសំណើបកស្រាយច្បាប់ ព្រោះវាស្នើឱ្យមានការប្រកាសច្បាប់ជាធរមាននៅ អ.វ.ត.ក។

១១. សហចៅក្រមស៊ើបអង្កេតបានចេញដីកាមួយចំនួនបដិសេធសំណើសុំបកស្រាយច្បាប់ ហើយដីកាទាំងនេះកំណត់យ៉ាងច្បាស់នូវមូលហេតុលម្អិតចំពោះការបដិសេធ និងបានជូនដំណឹងដល់ភាគីផ្សេង[១០]។ សហចៅក្រមស៊ើបអង្កេតបានដាស់តឿនសហមេធាវីការពារក្ដី អៀង សារី អំពីបញ្ហានេះនៅក្នុងដីការបស់ខ្លួនចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១០[១១]។ សហចៅក្រមស៊ើបអង្កេត មិនតម្រូវឱ្យធ្វើបុរេវិនិច្ឆ័យចំពោះការកំណត់ប្រភេទបទល្មើសនៃអង្គហេតុនោះទេ ជាពិសេសនៅពេលដែលខ្លួនមិនទាន់ចេញដីកាដំណោះស្រាយ។ សហចៅក្រមស៊ើបអង្កេតមិនមើលឃើញសារសំខាន់ក្នុងការធ្វើសំអាងហេតុច្រំដែលៗ នៃការបដិសេធចេញសេចក្ដីសម្រេចបកស្រាយច្បាប់នោះទេ។

១២. ដោយផ្អែកលើហេតុផលខាងលើ សហចៅក្រមស៊ើបអង្កេតនឹងមិនពិចារណាសំណើទីមួយដែលសហមេធាវីកាពារក្ដី អៀង សារី បានដាក់កាលពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១០ ទេ។ សហចៅក្រមស៊ើបអង្កេត នៅពេលរៀបចំសេចក្ដីព្រាងដីកាដំណោះស្រាយ នឹងយកចិត្តទុកដាក់ចំពោះបញ្ហាអង្គច្បាប់ទាក់ទងនឹងការទទួលខុសត្រូវរបស់មេកើយ។

---

[៨] D345/2

[៩] D345/2 កថាខណ្ឌ១

[១០] សូមមើលឧទាហរណ៍នៅ D240/3 កថាខណ្ឌ ៣-៥, D268/2 កថាខណ្ឌ ៩-១១ និង D180/6 កថាខណ្ឌ៦-៨។ មានករណីលើកលែងតែមួយគត់ ដែលសហចៅក្រមស៊ើបអង្កេតបន្តបដិសេធសំណើបកស្រាយច្បាប់ នោះគឺ ដីកាសម្រេចអំពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវ ដែលត្រូវបានស្គាល់ថាជា សហឧក្រិដ្ឋកម្មរួម (D97/13)។ ការផ្ដល់មូលហេតុនៅក្នុងការចេញដីកានេះមិនអាចអនុវត្តចំពោះទម្រង់នៃការទទួលខុសត្រូវ ដូចជា ការទទួលខុសត្រូវរបស់ថ្នាក់លើទេ ដែលមានចែងយ៉ាងច្បាស់នៅក្នុងមាត្រា២៩ (ថ្មី) នៃច្បាប់ អ.វ.ត.ក។ សូមមើល D240/3 កថាខណ្ឌ៣-៥

[១១] D345/1 កថាខណ្ឌ៥

00487599



**អាស្រ័យហេតុនេះ**

- **សម្រេច បដិសេធ**សំណើសុំទីមួយ និងសំណើជម្រើសដែលដាក់ដោយក្រុមមេធាវីការពារក្តី អៀង សារី ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០១០ (D345/2- និង D345/3)។

- **កត់សម្គាល់ថា** ការកំណត់ប្រភេទបទល្មើសនឹងត្រូវធ្វើឡើងនៅក្នុងដីកាដំណោះស្រាយ បន្ទាប់ពីការវាយតម្លៃលើភស្តុតាងដែលមានក្នុងសំណុំរឿងចប់រួចរាល់។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែមីនា ឆ្នាំ ២០១០

**សហចៅក្រមស៊ើបអង្កេត**

**Co-Investigating Judges**

**Co-juges d'instruction**

**Marcel LEMONDE** យូ ប៊ុនឡេង